ព័ត៌មានសង្ខេប

# បន្ទុកសេដ្ឋកិច្ចនៃអំពើហិង្សាលើកុមារ

## អំពើហិង្សាគឺជារឿងទូទៅនៅក្នុងជីវិតកុមារកម្ពុជាជាច្រើន



### អំពើហិង្សាផ្លូវកាយ

**កុមារី និងកុមារា ១នាក់ក្នុងចំណោម ២នាក់អាយុក្រោម១៨ឆ្នាំបានទទួលរងអំពើហិង្សាផ្លូវកាយ។**

**សកម្មភាពហិង្សាផ្លូវកាយ** រួមមាន ការទះកំផ្លៀង ការច្រាន ការដាល់ ការទាត់ធាក់ ការវាយនឹងរំពាត់ ការវាយនឹងវត្ថុអ្វីមួយ ការធ្វើឱ្យស្លាក់ ការធ្វើឱ្យថប់ដង្ហើម ការព្យាយាមធ្វើឱ្យលង់ទឹក ដុតធ្វើឱ្យរលាក មានរបួស ឬគំរាមដោយប្រើប្រាស់អាវុធ ដូចជា កាំបិត ឬ អាវុធដទៃទៀត។



### អំពើហិង្សាផ្លូវចិត្ត

**កុមារី និងកុមារា ១នាក់ក្នុងចំណោម ៤នាក់អាយុក្រោម១៨ឆ្នាំបានទទួលរងអំពើហិង្សាផ្លូវចិត្ត។**

**អំពើហិង្សាផ្លូវចិត្ត** សំដៅចំពោះគំរូនៃការប្រព្រឹត្តិផ្ទាល់មាត់ជាបន្តបន្ទាប់ ឬ ហេតុការណ៍ដាច់ដោយឡែកមួយ ដែលមិនសមស្របសម្រាប់ការអភិវឌ្ឍ របស់កុមារ និង ដែលមានលទ្ធភាពខ្ពស់ក្នុងការបង្កការខូចខាតទៅលើសុខភាពផ្លូវចិត្ត ឬ ការអភិវឌ្ឍផ្លូវកាយរបស់កុមារ។ សកម្មភាពហិង្សាផ្លូវចិត្ត រួមមានដូចជា ការប្រាប់ ថាគ្មាននរណាស្រឡាញ់ ការដែលនរណាម្នាក់និយាយថា ឬ មានគេនិយាយថាអ្នកមិនបានកើតមកទើបប្រសើរជាង ឬ ការដែលត្រូវបានគេយកមកលេងសើច ឬ មិនផ្តល់តម្លៃ។



### អំពើហិង្សាផ្លូវភេទ

**កុមារី និងកុមារា ១នាក់ក្នុងចំណោម ២០នាក់អាយុក្រោម១៨ឆ្នាំបានទទួលរងរំលោភបំពានផ្លូវភេទ។**

**អំពើហិង្សាផ្លូវភេទ** រួមមាន រាល់គ្រប់ទម្រង់នៃអំពើរំលោភបំពានផ្លូវភេទ និងអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារដូចជាសកម្មភាពរួមភេទបានសម្រេចដោយគ្មានការយល់ព្រម (អំពើរំលោភផ្លូវភេទ) ការប៉ុនប៉ងធ្វើសកម្មភាពផ្លូវភេទដោយគ្មានការយល់ព្រម ការប៉ះពាល់ផ្លូវភេទដោយរំលោភបំពាន (ការប៉ះពាល់ដែលគេមិនចង់ឱ្យប៉ះ) និងការរំលោភបំពានផ្លូវភេទដោយគ្មានការប៉ះពាល់ (ឧ. ការគំរាមប្រព្រឹត្តអំពើហិង្សាផ្លូវភេទ ការបង្ហាញកេរ្តិ៍ភេទ ការបៀតបៀនផ្លូវភេទដោយពាក្យសម្តី)។

## អំពើហិង្សាកាលពីកុមារភាព បណ្តាលឱ្យសុខភាពផ្លូវកាយ និងផ្លូវចិត្តមានភាពទន់ខ្សោយ និងមានការប្រព្រឹត្តិដែលមានការប្រឈម



### សម្រាប់កុមារាអំពើហិង្សាកាលពីកុមារភាព មានទំនាក់ទំនងទៅនឹង៖

**អំពើហិង្សាផ្លូវកាយ**
- ការជក់បារី
- ការទទួលទានសុរា
- របួសស្នាមមធ្យម

**អំពើហិង្សាផ្លូវចិត្ត**
- ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង
- វិបត្តិផ្លូវចិត្ត
- ការប្រព្រឹត្តិអំពើហិង្សាដោយដៃគូស្និទ្ធស្នាល
- របួសស្នាមមធ្យម

**អំពើរំលោភបំពានផ្លូវភេទ**
- ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង
- ជំងឺកាមរោគ



### សម្រាប់កុមារីអំពើហិង្សាកាលពីកុមារភាពមានទំនាក់ទំនងទៅនឹង៖

**អំពើហិង្សាផ្លូវកាយ**
- ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង
- ជំងឺកាមរោគ
- វិបត្តិផ្លូវចិត្ត
- ការទទួលទានសុរា
- ការប្រព្រឹត្តអំពើហិង្សាដោយដៃគូស្និទ្ធស្នាល
- របួសស្នាមមធ្យម

**អំពើហិង្សាផ្លូវចិត្ត**
- ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង
- ជំងឺកាមរោគ
- ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង
- ការប្រព្រឹត្តិអំពើហិង្សាដោយដៃគូស្និទ្ធស្នាល
- របួសស្នាមមធ្យម

**អំពើរំលោភបំពានផ្លូវភេទ**
- ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង
- ជំងឺកាមរោគ
- ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង
- ការប្រព្រឹត្តិអំពើហិង្សាដោយដៃគូស្និទ្ធស្នាល

# បន្ទុកសេដ្ឋកិច្ច

- ផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចនៃអំពើហិង្សាលើកុមារ រួមមានការបន្ថែមបន្ទុកទៅលើប្រព័ន្ធថែទាំសុខភាព ដោយសារតែការប្រើប្រាស់សេវាសុខភាពដ៏លើសលប់ និងក្នុងករណីធ្ងន់ធ្ងរ គឺបណ្តាលឱ្យមានពិការភាព និង មរណភាពព្រមទាំងកម្រិតនៃអំពើហិង្សា និងពិរុទ្ធភាពមានការកើនឡើង។
- ការសិក្សាបានពិនិត្យមើលទៅលើចំនួនផលវិបាកផ្នែកសុខភាពនៃអំពើហិង្សា និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច។



យ៉ាងហោចណាស់មាន ការបាត់បង់ថវិកាចំនួន **១៦៨**លានដុល្លារ សហរដ្ឋអាមេរិកក្នុងឆ្នាំ **២០១៣**

ដោយសារតែផលវិបាក អវិជ្ជមានផ្នែកសុខភាព មួយចំនួនដែលបង្កឡើង ដោយអំពើហិង្សាលើកុមារ

អំពើហិង្សាកាលពីកុមារភាពបាន បណ្តាលឱ្យខាតបង់ផលិតភាព គិតជាសាច់ប្រាក់ចំនួន

**៨៣,៣លាន ដុល្លារសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០១៣**

នេះគ្រាន់ជាសញ្ញាណតូចមួយប៉ុណ្ណោះ អាស្រ័យដោយសារមានតែផលវិបាកផ្នែកសុខភាព មួយចំនួនដែលត្រូវបានកំណត់ជ្រើសរើសដើម្បីធ្វើ ការប៉ាន់ប្រមាណទៅលើថ្លៃចំណាយហិរញ្ញវត្ថុ សម្រាប់គោលបំណងនៃការសិក្សានេះ

បន្ទុកសេដ្ឋកិច្ចនៃផលវិបាកសុខភាព មួយចំនួននៃអំពើហិង្សាលើកុមារដែល បានជ្រើសរើសមានតម្លៃប្រមាណ **១,១០%នៃផលិតផលក្នុងស្រុក សរុបរបស់ប្រទេសកម្ពុជា។**

ការខាតបង់ផលិតផល ដោយសារតែអំពើហិង្សាកាលពី កុមារភាពមានតម្លៃប្រមាណ **០,៥៥%នៃផលិតផលសរុបស្រុក របស់ប្រទេសកម្ពុជា។**

!

- មានតម្រូវការជាបន្ទាន់ ក្នុងការវិនិយោគទៅលើប្រព័ន្ធកិច្ចការពារកុមារកំរិតជាតិ ដើម្បីធានាថាកុមារ និងយុវជនគ្រប់រូប ដែលបានទទួលរងអំពើហិង្សា មានលទ្ធភាពទទួលបានការថែទាំប្រសើរបំផុត ព្រមទាំងទទួលបានការឆ្លើយតបដែលនឹងជួយធានាឱ្យមានភាពធូរស្រាលឡើងវិញនិងធ្វើឱ្យជនល្មើសទទួលខុសត្រូវ។
- ការបង្ការ និងការទប់ស្កាត់អំពើហិង្សាលើកុមារ មានប្រយោជន៍ចំពោះមនុស្ស និងសេដ្ឋកិច្ចដ៏ធំធេងសម្រាប់សង្គមជាតិកម្ពុជាទាំងមូល។ កុមារដែលចម្រើនវ័យឡើងនៅក្នុងបរិយាកាសអហិង្សានឹងមានឱកាសប្រសើរជាងក្នុងការឈានទៅសម្រេចឱ្យបាននូវសក្តានុពលពេញលេញរបស់ពួកគេ និងក្លាយជាមនុស្សពេញវ័យដែលមានសុខភាពល្អ និងមានផលិតភាពខ្ពស់។
- ការវិនិយោគក្នុងថ្ងៃនេះមានប្រសិទ្ធភាពផ្នែកចំណាយខ្ពស់ជាងការមិនវិនិយោគ។ **កិច្ចការពារកុមារ មិនត្រឹមតែជារឿងដ៏ត្រឹមត្រូវដែលត្រូវធ្វើប៉ុណ្ណោះទេ ប៉ុន្តែវាគឺជារឿងដ៏វៃឆ្លាតដែលត្រូវធ្វើ។**